ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 03 / 2012
ម៉ោង (Time/Heure): 10 : 35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសង
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន**
ចៅក្រម Claudia FENZ
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១២

ភាសាដើម: ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ក.ស.ច.ស

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**
នួន ជា
អៀង សារី
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Michiel PESTMAN
Victor KOPPE

Andrew IANUZZI
Jasper PAUW
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN

00788414



## ១. សេចក្តីផ្តើម

១. ក្រុមមេធាវីការពារក្តី នួន ជា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន៣៥ (២) (ខ) នៃវិធានផ្ទៃក្នុង ដើម្បីសម្រេច ថាតើអ្នកស៊ើបអង្កេតពិតជាបានបន្ទុចបង្អាក់កិច្ចស៊ើបសួរលើសំណុំរឿង ០០២ ដោយដឹងច្បាស់ និងដោយចេតនា តាមមធ្យោបាយបំប្លែងភស្តុតាងដោយខុសច្បាប់ពិតមែន ឬយ៉ាងណា[១]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានទទួលផងដែរ នូវលិខិតមួយពីក្រុមមេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១១ ដោយស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់ឲ្យភាគីនានា នូវប្រតិចារឹកទាំងស្រុង នៃកិច្ចសម្ភាសន៍ទាំងអស់ ធ្វើឡើងដោយ ក.ស.ច.ស ជាមួយសាក្សីដែលត្រូវបានកំណត់ពេលឲ្យចូលធ្វើសក្ខីកម្ម និងការបកប្រែប្រតិចារឹកទាំងនោះជាភាសាអង់គ្លេស និងភាសាខ្មែរ[២]។

២. នៅក្នុងអនុស្សរណៈមួយ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង លើកឡើងអំពីផលប៉ះពាល់នៃសំណើទាំងនេះលើផ្នែកគ្រប់គ្រងតុលាការ ("CMS") និងអង្គភាពបកប្រែភាសា ("ITU")[៣]។ សេចក្តីសម្រេចនេះ សម្រេចទៅលើខ្លឹមសារនៃសំណើទាំងនេះ។ នៅក្នុងសេចក្តីសម្រេចមួយដែលកំពុងតែរៀបចំដោយអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះនឹងដោះស្រាយផលប៉ះពាល់នៃចំណុចមិនស៊ីសង្វាក់គ្នាដែលត្រូវបានលើកឡើង រវាងខ្សែអាត់សំឡេង និងកំណត់ហេតុនៃការស្តាប់ចម្លើយ ដែលសហព្រះរាជអាជ្ញា ស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយមិនមានវត្តមានអ្នកផ្តល់ចម្លើយទាំងនេះផ្តល់សក្ខីកម្មក្នុងពេលសវនាការ[៤]។

---

[1] សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ក.ស.ច.ស ឯកសារលេខ D142 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ (សំណើរបស់ នួន ជា)។

[2] លិខិតរបស់ក្រុមមេធាវីការពារក្តី លោក អៀង សារី ទាក់ទិននឹងប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយសាក្សី ឯកសារលេខ E142/1 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១១។

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង "សំណើសុំបកប្រែភាសាដើម្បីគាំទ្រដល់សំណើសុំ E142 របស់ជនជាប់ចោទ នួន ជា និងលិខិតរបស់ជនជាប់ចោទ អៀង សារី ផ្ញើមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១១ " (E142/1) ឯកសារ E142/2 ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១")។

[4] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៩២ ឯកសារ E 96 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។

**២. សារណា**

៣. ក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថា កំណត់ហេតុនៃការស្តាប់ចម្លើយ និងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស "បង្ហាញពីលក្ខណៈគ្រប់គ្រាន់នៃចំណុចមិនស៊ីសង្វាក់គ្នា" ដែល "ធ្វើឲ្យប៉ះពាល់ដល់ទំនុកចិត្តលើកិច្ចស៊ើបសួរទាំងស្រុង"[5]។ ក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថា តាមរយៈការពិនិត្យមើលកំណត់ហេតុ និងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សីចំនួន ០៦ រូប បង្ហាញថា មានចន្លោះប្រហោង និងភាពមិនស្របគ្នានៃអត្ថន័យ នៅក្នុងប្រតិចារឹកជាភាសាខ្មែរ និងកំណត់ហេតុនៃការស្តាប់ចម្លើយជាភាសាអង់គ្លេស ហើយខ្សែអាត់សំឡេងមិនមានភាពពេញលេញ[6]។ ឧទាហរណ៍ ក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថា ក.ស.ច.ស បានកែប្រែចម្លើយធម្មតាឲ្យក្លាយជាចម្លើយដាក់បន្ទុក ដោយ "ចាត់ទុកការយល់ស្របរបស់សាក្សីទៅនឹងសំណួរដឹកមុខនានារបស់ខ្លួនថាសាក្សីពិតជាយល់ដឹងច្បាស់លាស់" និងថា ក.ស.ច.ស បានសង្ខេបចម្លើយសាក្សី ដោយពុំមានលំដាប់លំដោយត្រឹមត្រូវ ដើម្បីសរសេររឿងរ៉ាវមួយឲ្យមានភាពស៊ីសង្វាក់គ្នា ដែលមើលទៅហាក់បីដូចជាកំណត់ហេតុត្រឹមត្រូវ តែតាមការពិតមិនដូច្នេះឡើយ[7]។

៤. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីលោក នួន ជា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងស៊ើបអង្កេត "ឲ្យបានល្អិតល្អន់ និងប្រកបដោយប្រសិទ្ធភាព" អនុលោមតាមវិធាន ៣៥ (២) (ខ) ដើម្បីសម្រេច ថាតើអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ពិតជាបានបន្ទុចបង្អាក់កិច្ចស៊ើបសួរលើសំណុំរឿង ០០២ ដោយដឹងច្បាស់ និងដោយចេតនា តាមមធ្យោបាយបំប្លែងភស្តុតាងដោយខុសច្បាប់ពិតមែន ឬយ៉ាងណា[8]"។ ក្រុមមេធាវីការពារក្តី នួន ជា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងប្រគល់ជូនភាគីនូវប្រតិចារឹកជាលាយលក្ខណ៍អក្សរ នៃការស្តាប់ចម្លើយសាក្សីសំខាន់ៗទាំងអស់ ដែលត្រឹមត្រូវគ្មានការកែប្រែ និងស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវបានកំណត់ឲ្យចូលធ្វើសក្ខីកម្ម មុនពេលកោះហៅសាក្សីនីមួយៗឲ្យមកផ្តល់សក្ខីកម្ម។ ក្រុមមេធាវីការពារក្តី ក៏បានស្នើឲ្យ "ចាត់វិធានការបន្ថែមនានាដែលអង្គជំនុំជម្រះសាលាដំបូង យល់ថាចាំបាច់ អាស្រ័យទៅតាមលទ្ធផលនៃការ

---

[5] សំណើរបស់នួន ជា កថាខណ្ឌ ៣,១៧

[6] សំណើរបស់នួន ជា កថាខណ្ឌ ២,៤-៧

[7] សំណើរបស់នួន ជា កថាខណ្ឌ ៤ (យោងទៅលើកំណត់ត្រាស្តាប់ចម្លើយសរុបចំនួន ១៣)

[8] សំណើរបស់នួន ជា កថាខណ្ឌ ២៥ (ក)

ស៊ើបអង្កេតរបស់ខ្លួន[9]”។

៥. ក្នុងសំណើរបស់ខ្លួន ក្រុមមេធាវីការពារក្តី នួន ជា ក៏បានជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំអនុញ្ញាតឱ្យសាក្សីរំឭកការចងចាំរបស់ខ្លួន ដោយអានចម្លើយមុនៗរបស់ពួកគាត់មុនពេលផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[10]។ កាលថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានពន្យល់ពីមូលហេតុនៃការបង្ហាញចម្លើយមុនៗឱ្យសាក្សី មុនពេលធ្វើសក្ខីកម្មនៅសវនាការ និងបានផ្តល់គោលការណ៍ណែនាំដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងនឹងកិច្ចការនេះ[11]។

## ៣. ផ្នែកសំអាងហេតុ

៦. វិធានផ្ទៃក្នុង ចែងអំពីនីតិវិធីដើម្បីការពារសុចរិតភាពនៃកិច្ចស៊ើបសួរ និងភាពត្រឹមត្រូវនៃកំណត់ត្រា[12]។ សហចៅក្រមស៊ើបអង្កេត អាចស្តាប់ចម្លើយជនរងគ្រោះ ឬសាក្សីដោយផ្ទាល់ និងកត់ត្រាចម្លើយរបស់សាក្សីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី។ ទោះជាយ៉ាងណា សហ-ចៅក្រមស៊ើបអង្កេត ក៏អាចផ្ទេរអំណាចឱ្យអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ អ្នកស៊ើបអង្កេត ត្រូវបំពេញកិច្ចស៊ើបសួរក្រោមការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍

---

[9] សំណើរបស់ នួន ជា កថាខណ្ឌ ២៥ (ខ)-(គ)

[10] សំណើរបស់ នួន ជា កថាខណ្ឌ ២២-២៤

[11] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង “ការប្រគល់ចម្លើយមុនៗឱ្យសាក្សីមុនពេលធ្វើសក្ខីកម្មនៅសវនាការ” ឯកសារលេខ E141/1 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (“អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១”) (បញ្ជាក់ថាការផ្តល់ចម្លើយមុនៗឱ្យសាក្សី មុនពេលធ្វើសក្ខីកម្មនៅសវនាការ គឺសំដៅបញ្ចៀសការខ្ជះខ្ជាយពេលវេលារបស់សវនាការ ប្រសិនបើសាក្សីត្រូវការរំឭកចម្លើយចាស់ៗរបស់ខ្លួន ឬបញ្ជាក់ថាចម្លើយទាំងនេះពិតជាចម្លើយរបស់ខ្លួនប្រាកដមែន)។

[12] *សូមមើល ឧទាហរណ៍* វិធាន ៥៥, ៦២ (ចែងនូវគោលការណ៍ខាងក្រោមនេះទាក់ទងនឹងការបំពេញកិច្ចស៊ើបសួរ៖ “ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ។” (វិធាន ៥៥ (៥) និងចំពោះគោលការណ៍ទាក់ទងនឹងការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស មានចែងក្នុងវិធាន ៥៥ (៩) និង ៦២ (២))។

អក្សរនៃការស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួររបស់ខ្លួន[១៣]។ លើសពីនេះ វិធានផ្ទៃក្នុងចែងថារាល់ការស្តាប់ចម្លើយ ឬ សួរយកចម្លើយទាំងអស់របស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុ[១៤] ប៉ុន្តែក្នុងកាលៈទេសៈដែលអាចធ្វើទៅបាន ការស្តាប់ចម្លើយ ឬ សួរយកចម្លើយត្រូវតែថតយកសំឡេង ឬ ថតរូបភាព[១៥]។ ហេតុដូច្នេះ វាមិនចាំបាច់ត្រូវថតយកសំឡេង ឬ ថតរូបភាពនៃការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ការស្តាប់ចម្លើយ ឬសួរយកចម្លើយភាគច្រើន ដោយ ក.ស.ច.ស ត្រូវបានថតយកសំឡេង ទោះជាវិធានផ្ទៃក្នុងមិនតម្រូវឱ្យធ្វើប្រតិចារឹក ឬបកប្រែខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ឬសួរយកចម្លើយក៏ដោយ។ ដោយសារធនធានមានកម្រិត ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយធ្វើឡើងដោយ ក.ស.ច.ស មិនត្រូវបានបកប្រែ និងធ្វើប្រតិចារឹកទេ។ ទោះជាយ៉ាងណា ខ្សែអាត់សំឡេង និងកំណត់ត្រាស្តាប់ចម្លើយ ត្រូវបានដាក់ចូលក្នុងសំណុំរឿងជាបន្តបន្ទាប់ ក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរ ហើយដូច្នេះភាគីមានលទ្ធភាពពិនិត្យមើលឯកសារទាំងនោះបាន (ទាំងអ្នកចេះភាសាខ្មែរ ភាសាអង់គ្លេស និង/ឬភាសាបារាំង) ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ បច្ចុប្បន្ននេះ សំណុំរឿងផ្ទុកនូវកំណត់ត្រាចំនួនជាង ៧៥០ កំណត់ត្រានៃការស្តាប់ចម្លើយសាក្សីដោយ ក.ស.ច.ស ក្នុងដំណាក់កាលស៊ើបសួរក្នុងសំណុំរឿង០០២[១៦]។

៧. ភាគីគប្បីបានដាក់សំណើទៅអង្គបុរេជំនុំជម្រះ ឱ្យធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយ ឬ កិច្ចស៊ើបសួរទាំងមូល ដោយអនុលោមតាមវិធាន៧៦ នៅពេលខ្លួនអះអាងថា មានការបំប្លែងកំណត់ហេតុនៃកិច្ចស្តាប់ចម្លើយ ដើម្បីបំប្លែងខ្លឹមសារនៃចម្លើយសាក្សីដោយចេតនា និងដោយ

---

[13] *សូមមើល* វិធាន ៦២ (៣) (ក)។ ទោះជាក្រុមមេធាវីការពារក្តីលោក នួន ជា លើកឡើងក្នុងសំណើរបស់ខ្លួន (កថាខណ្ឌ ១៤) ថាវិធាន ៦២ (៣) (ក) នៃវិធានផ្ទៃក្នុង តម្រូវឱ្យអនុវត្តស្របទៅនឹង "បទប្បញ្ញត្តិនៃវិធាន ៥១ (៨) នៃវិធានផ្ទៃក្នុងតាមករណីសមស្រប" ក៏ដោយ ក៏វិធាន៦៣ (២) (ក) តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត "ធ្វើកំណត់ហេតុអំពីរយៈពេលសម្ភាសន៍ និងរយៈពេលសម្រាកចន្លោះពេលសម្ភាសន៍"។ ភាពជាប់ទាក់ទងនៃបទប្បញ្ញត្តិក្នុងវិធាន ៥១ (៨) ដែលត្រូវបានយោង មានកម្រិត ដោយហេតុថាបទប្បញ្ញត្តិនេះ ទាក់ទងតែទៅនឹងនីតិវិធីធ្វើរបាយការណ៍ស្តីពីការឃាត់ខ្លួនបុគ្គលណាម្នាក់ដោយនគរបាលយុត្តិធម៌។ វិធាននេះ អាចអនុវត្តបានតែចំពោះ "បុគ្គលណាម្នាក់ ដែលសង្ស័យថាបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ" តែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ បទប្បញ្ញត្តិទាំងនេះ មិនទាក់ទងទៅនឹងការស្តាប់ចម្លើយសាក្សីទេ។

[14] *សូមមើល* វិធាន ៥៥ (៧) នៃវិធានផ្ទៃក្នុង

[15] *សូមមើល* វិធាន ២៥ នៃវិធានផ្ទៃក្នុង

[16] *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រទី២។

ដឹងច្បាស់ និងធ្វើឱ្យរាំងស្ទះដល់កិច្ចស៊ើបសួរ។ អាស្រ័យហេតុនេះ ក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូង នឹងមិនពិចារណាបញ្ហាណាដែលគួរត្រូវបានដោះស្រាយក្នុងអំឡុងពេលស៊ើបសួរឡើយ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូង នឹងពិចារណាបញ្ហានេះ ក្នុងករណីភាគីអាចបង្ហាញថា ពួកគាត់មិនមានឱកាសរកឱ្យឃើញនូវការបំភ្លៃង ដែលត្រូវបានចោទប្រកាន់ នៅមុនពេលបើកសវនាការលើអង្គសេចក្តី ឬក្នុងករណីមានភាពចាំបាច់ដើម្បីគាំពារភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី[១៧]។

៨. ក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរ ភាគីទាំងអស់ ត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលឯកសារក្នុងសំណុំរឿង ក្នុងនោះខ្សែអាត់សំឡេងផងដែរ។ ក្រុមមេធាវីការពារក្តី នួន ជា មិនបានធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ខ្លួនមិនអាចវាយតម្លៃអំពីការបំភ្លៃងភស្តុតាងដែលគួរឱ្យជឿបាននូវកំណត់ហេតុនៃការស្តាប់ចម្លើយ នៅមុនពេលបើកសវនាការឡើយ។ ទោះយ៉ាងណាក៏ដោយ ដោយហេតុថា ការចោទរបស់ក្រុមមេធាវីការពារក្តី នួន ជា មានភាពធ្ងន់ធ្ងរ ហើយការចោទនេះអាចប៉ះពាល់លើភាពយុត្តិធម៌នៃការជំនុំជម្រះក្តី អង្គជំនុំជម្រះសាលាដំបូង បានវាយតម្លៃថាតើមានសំអាងហេតុគ្រប់គ្រាន់ ដើម្បីបន្តពិចារណាសំណើរបស់នួន ជា ដែរ ឬទេ។

៩. សំណើនាពេលបច្ចុប្បន្នសុំឱ្យមានការស៊ើបអង្កេត ទៅលើកិច្ចស៊ើបសួរក្នុងសំណុំរឿង០០២ទាំងមូល ដោយអនុលោមតាមវិធាន៣៥(២)(ខ) នៃវិធានផ្ទៃក្នុង។ អនុវិធាននេះផ្តល់អំណាចឱ្យអង្គជំនុំជម្រះសាលាដំបូងបំពេញកិច្ចស៊ើបសួរ "នៅពេល [...អង្គជំនុំជម្រះមាន] ហេតុផលគួរឱ្យជឿថា បុគ្គលណាម្នាក់បានជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយចេតនាពិតប្រាកដ"[18]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានគូសបញ្ជាក់អំពីក្របខ័ណ្ឌគតិយុត្តជាធរមានសម្រាប់សំណើសុំបើកកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង[19]។ ការធ្វើអន្តរាគមន៍ ដោយអនុលោមតាមវិធាននេះ អាចធ្វើទៅបាន លុះត្រាតែមានការជឿជាក់ដោយមានហេតុផលសមស្របថា បុគ្គលណាម្នាក់បានជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំ

---

[17] សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការជេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ឯកសារលេខ E71/1 ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១។

[18] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ, ឯកសារ D158/5/1/15, ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩, កថាខណ្ឌ ២៩។

[19] សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E 82, E 88 និង E 92) ឯកសារ E116, ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ២១-២២។

ជម្រះ "ដោយចេតនាពិតប្រាកដ"។ យុត្តិសាស្ត្រពាក់ព័ន្ធបានបញ្ជាក់ថា សំណើដែលបានស្នើ ដោយអនុលោមតាមអនុវិធាននេះត្រូវមានហេតុផលសំអាងត្រឹមត្រូវ ហើយជំនួសមកវិញ គេពុំអាចស្នើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីសបញ្ជាក់ថាតើមានហេតុផលត្រឹមត្រូវដែរ ឬទេ នោះឡើយ[20]។

១០. ដូច្នេះ នៅពេលមានការតវ៉ាអំពីភាពត្រឹមត្រូវនៃទង្វើរបស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ឬនៅពេលមានការចោទប្រកាន់អំពីការបំប្លែង ឬការបង្ខូចភស្តុតាង ម្ចាស់បណ្តឹងនឹងទទួលបន្ទុក ក្នុងការបង្ហាញថា ការសន្មតថាសកម្មភាពរបស់ ក.ស.ច.ស មានភាពប្រក្រតី ពុំគួរយកមកអនុវត្តតទៅទៀតឡើយ។ ជាក់ស្តែង កាលពីពេលថ្មីៗ ការសន្មតនេះត្រូវបានបដិសេធដោយសេចក្តីសម្រេចសម្តែងភាគតិចរបស់អង្គបុរេជំនុំជម្រះ (ពាក់ព័ន្ធនឹងការកែប្រែឯកសារដោយចេតនា និងដោយពុំត្រឹមត្រូវ)[21] ប៉ុន្តែជំនួសមកវិញ ការសន្មតដូចខាងលើត្រូវបានតម្កល់នៅពេលណាបណ្តឹងទាំងនោះត្រូវបានចាត់ទុកថា ជាបណ្តឹងដែលផ្អែកលើការសន្និដ្ឋាន ឬគ្មានភស្តុតាង[22]។

---

[20] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright, ឯកសារ E137/5, ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ១៤ (ដែលបញ្ជាក់ថាសំណើសុំបំពេញកិច្ចស៊ើបសួរពុំមែនជាយន្តការសមស្របដើម្បីទទួលបានភស្តុតាងគាំទ្របណ្តឹងជំទាស់ឡើយ)។

[21] *សូមមើល* សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច ស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លោក Robert Hamill, ឯកសារ D11/2/4/4, ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១, យោបល់របស់ចៅក្រម Lahuis និងចៅក្រម Downing (ដែលបានបង្ហាញវិការៈនីតិវិធីនានានៅក្នុងកិច្ចស៊ើបសួរ រួមបញ្ចូលទាំងការជូនដំណឹងអំពីបទចោទ ការជូនដំណឹងទៅមនុស្សដែលអាចជាជនរងគ្រោះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ការពន្យារពេលនៃការដាក់ឯកសារ និងការជូនដំណឹងរបស់ខ្លួន); *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យ កោះហៅសាក្សី, ឯកសារ D314/2/7, ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០, កថាខណ្ឌ ៣៨។ ("វិធាន ៣៥ ត្រូវបានដាក់បញ្ចូលទៅក្នុងវិធានផ្ទៃក្នុង ក្នុងលក្ខណៈជាយន្តការមួយដើម្បីរក្សាបាននូវសុចរិតភាពនៃដំណើរការតាមផ្លូវតុលាការទាំងនៅដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ សុចរិតភាពនៃដំណើរការនេះ ត្រូវបានធានាតាមរយៈការអនុវត្តតាមផ្លូវតុលាការនូវវិធាននេះ នៅពេល ស.ច.ស ឬអង្គជំនុំជម្រះយល់ថា ទង្វើរបស់បុគ្គលណាម្នាក់គំរាមកំហែងដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ ការអនុវត្តបញ្ញត្តិនេះ [...] ដើរតួនាទីជាឧបសគ្គសម្រាប់ភាគីផ្សេងដែលអាចយល់ថាជាការជះឥទ្ធិពលដល់ដំណើរការនេះ")។

[22] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright, ឯកសារ E137/5, ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១១។

១១. អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា អនុលោមតាមទម្លាប់អនុវត្តទូទៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការស្ដាប់ចម្លើយចំពោះមុខ ក.ស.ច.ស ពុំមែនជាកំណត់ហេតុឥតលម្អៀងឡើយ ប៉ុន្តែវាជារបាយការណ៍ដែលសហចៅក្រមស៊ើបអង្កេតបានរៀបចំស្ដីពីចម្លើយពាក់ព័ន្ធរបស់សាក្សីដើមបណ្ដឹងរដ្ឋប្បវេណី ឬជនជាប់ចោទ[23]។ ជាងនេះទៅទៀត កំណត់ហេតុជាលាយលក្ខណ៍អក្សរនីមួយៗ រួមទាំងកំណត់ហេតុទាំងឡាយដែលមេធាវីការពារជនជាប់ចោទ នួន ជា បានពិនិត្យមើលឡើងវិញ បញ្ជាក់ថាកាលពីពេលនោះ ចម្លើយនោះត្រូវបានអានឱ្យម្ចាស់ចម្លើយស្ដាប់រួចរាល់ហើយ។ ម្ចាស់ចម្លើយបានបញ្ជាក់ភាពត្រឹមត្រូវនៃខ្លឹមសារចម្លើយ តាមរយៈការចុះហត្ថលេខា ឬស្នាមមេដៃ[24]។

១២. អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា ខ្លួននឹងពិចារណាមួយករណីម្ដងៗ ទៅលើការតវ៉ាអំពីសក្ខីកម្មរបស់សាក្សីនៅសវនាការ ដោយផ្អែកលើចំណុចមិនស៊ីសង្វាក់រវាងចម្លើយ និងកំណត់ហេតុជាខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយមុនៗ ត្រង់ចំណុចពាក់ព័ន្ធ[25]។ ទោះបីជាដូច្នេះក្ដី អង្គជំនុំជម្រះនឹងពិចារណាអំពីការចោទប្រកាន់អំពីចំណុចមិនស៊ីសង្វាក់ រវាងកំណត់ហេតុជាខ្សែអាត់សំឡេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ នៅពេលមានការចង្អុលបង្ហាញច្បាស់លាស់គ្រប់គ្រាន់អំពីចំណុចមិនស៊ីសង្វាក់នេះ ហើយនៅពេលភាពមិនស៊ីសង្វាក់នោះ ទាក់ទិននឹងចំណុចខ្វះចន្លោះនៃខ្លឹមសារដែលត្រូវបានចោទប្រកាន់ ដែលមានភាពពាក់ព័ន្ធជាក់ស្ដែងទៅនឹងសវនាការ។ លើសពីនេះ ភាគីណាដែលលើកការជំទាស់ត្រូវមានបន្ទុកបង្ហាញឱ្យបានច្បាស់លាស់ នូវចំណុចមិនស៊ីសង្វាក់ដែលត្រូវបានចោទប្រកាន់ និងជូនដំណឹងឱ្យបានទាន់ពេលវេលាមកអង្គជំនុំជម្រះ និងភាគីអំពីការចោទប្រកាន់អស់ទាំងនេះ និងឯកសារពាក់ព័ន្ធ[26]។ ដើម្បីបញ្ចៀសការដាក់បន្ទុកលើសលុបលើផ្នែកគ្រប់គ្រងតុលាការ និងអង្គភាពបកប្រែភាសាជាមួយសំណើសុំបកប្រែ និងការធ្វើប្រតិចារឹកនៃសម្ភារៈក្នុងចំនួនដ៏ច្រើន

---

[23] *សូមមើលបន្ថែម* វិធាន ២៤ នៃវិធានផ្ទៃក្នុង (ដែលដាក់កាតព្វកិច្ចឱ្យសាក្សីធ្វើសម្បថ មុនពេលផ្ដល់ចម្លើយ) និងវិធាន ២៨ (២) និងវិធាន ២៥(១)(ក) នៃវិធានផ្ទៃក្នុង (ដែលផ្ដល់សិទ្ធិឱ្យសាក្សីបានដឹងអំពីសិទ្ធិរបស់ខ្លួនប្រឆាំងនឹងការមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ហើយការស្ដាប់ចម្លើយរបស់ខ្លួនត្រូវថតជាខ្សែអាត់សំឡេង)។

[24] កន្លងមក អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថាឯកសារចម្លងនៃកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ត្រូវបានផ្ដល់ឱ្យសាក្សីម្នាក់ៗមុនពេលសវនាការ (អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E141/1) ។ *សូមមើលផងដែរ* វិធានផ្ទៃក្នុង ២៥ (២) និង ៥៥ (៧)។

[25] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ២។

[26] អនុស្សរណៈដដែល។

ដែលភាពពាក់ព័ន្ធរបស់វាទៅនឹងសវនាការពុំទាន់ត្រូវបានបង្ហាញ អង្គជំនុំជម្រះធ្លាប់បានជូនដំណឹងថា សំណើសុំធ្វើប្រតិចារឹក និងសំណើសុំបកប្រែដើម្បីគាំទ្រសេចក្តីជំទាស់ទាំងនេះ ត្រូវបង្ហាញឱ្យបានជាក់លាក់នូវចំណុចមិនស៊ីសង្វាក់ និងកំហិតត្រឹមផ្នែកនានានៃចម្លើយ និងកំណត់ហេតុជាខ្សែអាត់សំឡេងពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់ថាមានចំណុចមិនស៊ីសង្វាក់គ្នាប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពុំពិចារណាលើសំណើសុំធ្វើប្រតិចារឹក និងសំណើសុំបកប្រែកំណត់ហេតុជាខ្សែអាត់សំឡេង ឬប្រតិចារឹក ទាំងស្រុងក្នុងចំនួនដ៏ច្រើនឡើយ[27]។

១៣. អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅពេលសាក្សីត្រូវបានកោះហៅឱ្យចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ភាគីអាចសួរសំណួរដោយផ្ទាល់ទៅសាក្សីស្តីអំពីចំណុចខ្វះចន្លោះពាក់ព័ន្ធផ្សេងៗដែលត្រូវបានចោទប្រកាន់ រវាងចម្លើយសាក្សី និងកំណត់ហេតុជាខ្សែអាត់សំឡេងរបស់ខ្លួន។ ប៉ុន្តែ អង្គជំនុំជម្រះសូមបដិសេធដំណោះស្រាយដែលមេធាវីការពារជនជាប់ចោទ នួន ជា បានស្នើ។ នៅក្នុងការចោទប្រកាន់អំពីចំណុចខ្វះចន្លោះរវាងកំណត់ហេតុជាខ្សែអាត់សំឡេង និងចម្លើយជាលាយលក្ខណ៍អក្សរ មេធាវីពុំបានបង្ហាញ ឬពុំបានព្យាយាមចង្អុលបង្ហាញថាបុគ្គលិក ក.ស.ច.ស ពិតជាបានបំប្លែងកំណត់ហេតុនៃកិច្ចស៊ើបសួរដោយចេតនាពិតប្រាកដឡើយ (ឧទាហរណ៍ តាមរយៈការបដិសេធលទ្ធភាពដែលថា ការបំប្លែងទាំងប៉ុន្មានដែលត្រូវបានចោទប្រកាន់ គឺអាចបណ្តាលមកពីកំហុសរបស់មនុស្ស ឬការសង្ខេបដែលពុំអាចជៀសផុតពីកំហុសដើម្បីបង្រួមកំណត់ហេតុជាខ្សែអាត់សំឡេងដ៏វែងមកជាកំណត់ហេតុសង្ខេបជាលាយលក្ខណ៍អក្សរ)។ ផ្ទុយទៅវិញ មេធាវីការពារជនជាប់ចោទ នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "បញ្ជាក់ថាតើមានមូលដ្ឋានគ្រប់គ្រាន់ដែរ ឬទេដើម្បីផ្តួចផ្តើមនីតិវិធីប្រឆាំងនឹងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស"[28] ដោយការស្នើសុំនេះបានបំពានលើលក្ខខណ្ឌសម្រាប់ការអន្តរាគមន៍របស់អង្គជំនុំជម្រះ ដូចដែលវិធាន ៣៥(២)(ខ) នៃវិធានផ្ទៃក្នុងបានតម្រូវ។

១៤. មេធាវីការពារជនជាប់ចោទ នួន ជា ពុំបានផ្តល់សំអាងណាមួយឡើយ សម្រាប់អំណះអំណាងដែលថាចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់នៅក្នុងចម្លើយមួយចំនួនតូច ដែលខ្លួនបាន

---

[27] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើង "បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5" ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131/1។

[28] សំណើរបស់ជនជាប់ចោទ នួន ជា, កថាខណ្ឌ ១។

ពិនិត្យមើលឡើងវិញនោះ បង្ហាញនូវការសង្ស័យអំពីភាពមិនលម្អៀងនៃកិច្ចស៊ើបសួររយៈពេល ៣ ឆ្នាំ លើសំណុំរឿង ០០២ ទាំងមូល។ ផ្ទុយមកវិញ ចំណុចដែលថា សាក្សីទាំងអស់ដែលចុងក្រោយបានបញ្ជាក់អំពីភាពពិត និងត្រឹមត្រូវនៃចម្លើយរបស់ពួកគេនៅក្នុងទម្រង់នៃកំណត់ហេតុដែលរៀបចំជាលើកចុងក្រោយនឹងនាំឲ្យមានការសន្និដ្ឋានផ្សេងពីនេះនោះ មិនអាចធ្វើឡើងដោយពុំមានភស្តុតាងផ្ទុយបានឡើយ។ បន្ថែមពីលើចំណុចនេះ ការណ៍ដែលថា ការស្តាប់យកចម្លើយរបស់ ក.ស.ច.ស ភាគច្រើន គឺត្រូវបានថតជាខ្សែអាត់សំឡេង ហើយកំណត់ហេតុជាខ្សែអាត់សំឡេងត្រូវបានដាក់ទៅក្នុងសំណុំរឿង គឺពុំស៊ីសង្វាក់ទៅនឹងការបង្អាក់កិច្ចស៊ើបសួរដោយចេតនាឡើយ។ លើសពីនេះ និងដូចដែលអង្គជំនុំជម្រះបានកត់សម្គាល់ខាងលើ ទោះក្រោមកាលៈទេសៈបែបណាក្តី ក៏មេធាវីការពារជនជាប់ចោទ នួន ជា នឹងទទួលបានការគាំពារថែមទៀតនូវលទ្ធភាពក្នុងការសួរសំណួរទៅសាក្សីទាំងឡាយនៅសវនាការ ស្តីពីចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់ នៅពេលដែលចំណុចមិនស៊ីសង្វាក់ដែលត្រូវបានចោទប្រកាន់អស់ទាំងនេះ ពាក់ព័ន្ធជាក់ស្តែងទៅនឹងការវាយតម្លៃអំពីតម្លៃជាភស្តុតាង ឬចាំបាច់សម្រាប់ការការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីសវនាការ។

១៥. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មេធាវីការពារជនជាប់ចោទ នួន ជា បានខកខានពុំបានលើកមូលដ្ឋានឲ្យបានគ្រប់គ្រាន់ ដើម្បីផ្តួចផ្តើមនីតិវិធី ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ប្រឆាំងសហចៅក្រមស៊ើបអង្កេត ឬបុគ្គលិកណាម្នាក់ដែលត្រូវបានបញ្ចេញឈ្មោះ ឬពុំត្រូវបានបញ្ចេញឈ្មោះ និងខ្វះមូលដ្ឋានក្នុងការបញ្ជាក់ភាពសមហេតុផល ដើម្បីធ្វើការស៊ើបអង្កេតលើកិច្ចស៊ើបសួរលើសំណុំរឿង ០០២ ទាំងស្រុងនោះទេ។

**តាមសំអាងហេតុដូចដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូង ÷**

**បដិសេធ** ចំពោះខ្លឹមសារនៃសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារជនជាប់ចោទ នួន ជា ដោយអនុលោមតាមវិធាន ៣៥(២)(ខ) នៃវិធានផ្ទៃក្នុង។

**ជូនដំណឹង** ទៅភាគីនានាថា ប្រសិនបើសាក្សីដែលត្រូវបានបង្ហាញអត្តសញ្ញាណនៅក្នុងកថាខណ្ឌ ៤ ដល់កថាខណ្ឌ ៧ នៃសំណើរបស់មេធាវីការពារជនជាប់ចោទ នួន ជា ត្រូវបានកោះហៅឲ្យចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២ ពួកគាត់អាចត្រូវបានភាគី ឬអង្គជំនុំជម្រះសួរនៅសវនាការអំពីបញ្ហាខ្វះចន្លោះ ដូចមានបង្ហាញនៅក្នុងកថាខណ្ឌខាងលើតាមការចាំបាច់ ដើម្បីវាយតម្លៃ អំពីតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ពួកគាត់ ឬដើម្បីការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីសវនាការ។

**បញ្ជាក់បន្ថែម** ថា សាក្សីណាម្នាក់ដែលត្រូវបានកោះហៅឲ្យចូលខ្លួនមកផ្តល់សក្ខីកម្មនៅក្នុងសវនាការលើសំណុំរឿង ០០២ អាចត្រូវបានចោទសួរអំពីចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់រវាងចម្លើយរបស់ពួកគាត់ ដែលបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេត ឬកំណត់ហេតុផ្ទាល់មាត់នៃការស្តាប់ចម្លើយរបស់ពួកគាត់ ដរាបណាចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់អស់ទាំងនេះមានភាពចាំបាច់សម្រាប់វាយតម្លៃ អំពីតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ពួកគាត់ ឬដើម្បីការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីសវនាការ និងត្រូវបានបង្ហាញជូនអង្គជំនុំជម្រះ និងភាគីបានជាក់លាក់គ្រប់គ្រាន់ និងទាន់ពេលវេលា ដោយអនុលោមតាមកថាខណ្ឌ ១២ នៃសេចក្តីសម្រេចនេះ។

**រំឭកឡើងវិញ** នូវសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ពាក់ព័ន្ធនឹងការយកចម្លើយមុនៗមកបង្ហាញដល់សាក្សី នៅមុនពេលពួកគាត់ផ្តល់សក្ខីកម្មនៅសវនាការ (ឯកសារ E141/1)។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**